# ខ្លឹមសារសង្ខេបអត្ថបទ

**Catherine Elliott, A Comparative Analysis of English and French Defences to Demonstrate the Limitation of the Concept of Loss of Control, in Alan Reed and Michael Bohlander, Loss of Control and Diminished Responsibility, Domestic, Comparative and International Perspectives, 2011, pp. 231-246.**

១. ការដោះសារ «ការបាត់បង់ការគ្រប់គ្រង» (loss of control: LoC) របស់ស្ត្រីរងហិង្សាពីប្តី (battered women) ក្នុងការវាយប្រហារលើប្តី ទាញចេញពីបាត់បង់ការគ្រប់គ្រង បណ្តាលមកពីការបង្កហេតុ (provocation) ក្នុងករណីប្តីតាមទាន់ប្រពន្ធកំពុងដេកជាមួយសាហាយ។ ការបង្កហេតុនេះ ក៏អាចជាមូលដ្ឋានសម្រាប់ការពារខ្លួនស្របច្បាប់ (self-defence:SD) ប្រសិនបើ គេចាត់ ថាវាជាការវាយប្រហារ ដែលនាំឲ្យមានការតបក្នុងទម្រង់ជា SD។ LoC ក្នុងករណីស្ត្រីរងហិង្សាពីប្តី ត្រូវបានទទួលយកជាការដោះសារ ដោយសារ៖ ១. លើកកម្ពស់សិទ្ធិស្ត្រី។ទី២. មានគោលបំណងជួយបន្ថយការទទួលខុសត្រូវ និងទី៣. សម្រាប់ការកំណត់ទោស។

២. ការដោះសារ LoC មានខ្លឹមសារជាន់គ្នានឹងធាតុផ្សំនៃ SD។ SD ទាមទារនូវការវាយប្រហារនឹងកើតភ្លាមៗ (imminent attack) ដែលនេះមិនទាមទារជាចម្បងសម្រាប់ ការវាយប្រហារដោយសារ LoC ក្នុងករណីវាយប្រហារដោយស្ត្រីទេ។ ទោះបីជាយ៉ាងនេះក្តី គម្លាតពេលវេលា រវាងការវាយប្រហារ និងការឆ្លើយតប មិនត្រូវយូរពេកទេ ពីព្រោះថា ករណីខ្លះ ជំនួសឲ្យវាយតប ជនរងគ្រោះ (អ្នកវាយតប) អាចគេច ឬស្វែងរកនូវជំនួយ។ បើមានករណីនេះមែន វាយជាការវាយប្រហារសងសឹក (វាយប្រហារខណៈប្តីកំពុងតែដេក, ទំ.២៣៣) ដែល ទាំង SD និង LoC មិនអាចជាការដោះសារទេ។

៣. LoC ក្នុងករណីប្តីវាយប្រហារប្រពន្ធផិត ឬ ស្ត្រីទទួលរងហិង្សាពីប្តី ខុសគ្នាដោយសារក្នុងករណីទី១ ប្តីមិនមែនជាជនរងគ្រោះទេ រីឯករណីទី២ ប្រពន្ធជាជនរងគ្រោះនៃអំពើហិង្សាធ្ងន់ធ្ងរ ដែលនាំឲ្យនាង LoC រហូតសម្លាប់ប្តី ក្នុងគោលបំណងរក្សាសុវត្ថិភាពខ្លួន (self-preservation) ឬវាយបង្កា ដោយសារការភ័យខ្លាចនូវទង្វើហិង្សានាអនាគតដោយប្តី។

៤. ស្តង់ដារសម្រាប់វាយតម្លៃ LoC របស់ស្ត្រី អនុលោមតាម Objective Test (ទំ.២៣៤) ដែលទាមទារនូវការពិចារណាកត្តាពាក់ព័ន្ធជាច្រើន។ ចៅក្រម ពិចារណា ផ្អែកតាមមូលដ្ឋាន «ស្ត្រីមានហេតុផល» (reasonable women, ទំ. ២៣៤)។ ភាគីអ្នកលើក LoC ជាការដោះសារ ជាអ្នកដាក់ភស្តុតាងបង្ហាញ ហើយបន្ទុកភស្តុតាងនឹងត្រូវបានផ្ទេរទៅរដ្ឋអាជ្ញា ក្នុងការបដិសេធក្នុងកម្រិតភស្តុតាងហួសពីវិមតិសង្ស័យ (beyond reasonable doubt) ថាមិនមាន LoC ទេ (ទំ. ២៤១)។ LoC មិនមែនជា

មូលដ្ឋានដោះសាររួចខ្លួនទាំងស្រុងទេ (full defence) តែជា partial defence ដែលជនល្មើសអាចទទួលទោសសម្រាល។

*៩.* ខុសពីប្រព័ន្ធអង់គ្លេស ច្បាប់ព្រហ្មទណ្ឌបារាំង មិនមានចែង LoC ក្នុងករណីស្ត្រីរងហិង្សាពីប្តីទេ។ ផ្ទុយទៅវិញ បទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសធ្ងន់ទៅវិញ ករណីវាយប្រហារដោយសហព័ទ្ធ (ស្ថិតក្នុងស្ថានទម្ងន់)។ ដូចនេះ តុលាការបារាំង ផ្តោតសំខាន់លើ ការការពារស្របច្បាប់ ឬស្ថានភាពចាំបាច់ (necessity) សម្រាប់ដោះស្រាយករណី LoC ដែលត្រូវបានចោទ (ទំ. ២៤៩)។

**ពាក្យគន្លឹះ៖** ការបង្កហេតុ, ការពារខ្លួនស្របច្បាប់, កម្រិត និងបន្ទុកភស្តុតាង, ស្ថានភាពចាំបាច់។